មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

CCIM

cambodian center for independent media

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

ខេមបូចា

CamboJA

Cambodian Journalists Allianc Association

# បញ្ឈប់ការគំរាមកំហែងនិងធ្វើទុកបុកម្នេញលើអ្នកសារព័ត៌មានឯករាជ្យ

***ភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១*** - មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) និងសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) មានការព្រួយបារម្ភជាខ្លាំង ដោយសារតែអ្នកសារព័ត៌មានវីអូឌី ត្រូវបានអាជ្ញាធររារាំងនិងគំរាមកំហែងជាបន្តបន្ទាប់នៅពេលពួកគាត់ចុះបំពេញការងារ។

កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ អាជ្ញាធរខណ្ឌព្រែកព្នៅជាង១០នាក់ដែលដឹកនាំដោយអភិបាលខណ្ឌ បានរារាំងនិងគំរាមអ្នកថតវីដេអូម្នាក់របស់វីអូឌីនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដែលបានចុះទៅផ្តិតយកទិដ្ឋភាពចំណតបណ្តោះអាសន្ននៃផ្ទះបណ្តែតទឹកនិងបែចិញ្ចឹមត្រីរបស់ជនជាតិវៀតណាមដែលអាជ្ញាធរជម្លៀសចេញពីទីតាំងមួយចំនួននៅក្នុងរាជធានីភ្នំពេញ។ លើសពីនេះ ក្រុមសមត្ថកិច្ចក៏បានថតរូបនិងបណ្ណសម្គាល់ខ្លួនរបស់អ្នកថតវីដេអូរូបនេះ ហើយគំរាមថា គាត់នឹងមានបញ្ហាប្រសិនបើមានរូបភាពឬវីដេអូណាមួយត្រូវបានផ្សព្វផ្សាយ។

ករណីនេះបានកើតឡើងតែមួយសប្តាហ៍ប៉ុណ្ណោះបន្ទាប់ពីអ្នកសារព័ត៌មានវីអូឌីត្រូវបានរារាំងនិងគំរាមកំហែងក្នុងហេតុការណ៍ដាច់ដោយឡែកមួយទៀត។ កាលពីព្រឹកថ្ងៃទី១១ ខែមិថុនា អ្នកសារព័ត៌មាននិងអ្នកថតវីដេអូរបស់វីអូឌីបានចុះទៅរាយការណ៍អំពីការដាក់ញត្តិរបស់អតីតសកម្មជនគណបក្សសង្គ្រោះជាតិប្រមាណ១០នាក់ ទៅកាន់តំណាងសហគមន៍អឺរ៉ុប (EU)។ អាជ្ញាធរខណ្ឌដូនពេញដែលមានគ្នាប្រមាណ៦០នាក់ បានហាមមិនឱ្យអ្នកសារព័ត៌មានថតរូបនិងវីដេអូ ដោយព្រមានថានឹងដកសម្ភារៈនិងបញ្ជូនទៅសាលាខណ្ឌប្រសិនជាហ៊ានល្មើស។

ចំណែកកាលពីថ្ងៃទី១១ ខែឧសភាកន្លងទៅ អាជ្ញាធរខេត្តពោធិ៍សាត់ដែលដឹកនាំដោយអភិបាលរងខេត្តម្នាក់ បានដកយកសម្ភារៈនិងហាមឃាត់អ្នកសារព័ត៌មានវីអូឌីម្នាក់មិនឱ្យថតរូបសកម្មភាពពលរដ្ឋនៅខេត្តកំពង់ឆ្នាំងតវ៉ាបិទកំណាត់ផ្លូវជាតិលេខ៥ ដែលជាប់ព្រំប្រទល់ខេត្តពោធិ៍សាត់ ដើម្បីទាមទារឱ្យអាជ្ញាធរដោះស្រាយវិវាទដីធ្លីរបស់ពួកគេ។

សកម្មភាពរារាំងនិងគំរាមកំហែងទាំងអស់ខាងលើនេះពីសំណាក់អាជ្ញាធរ គឺជាគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សេរីភាពសារព័ត៌មាន ដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញនិងច្បាប់ស្តីពីរបបសារព័ត៌មានដែលបានធានាដល់សិទ្ធិសេរីភាពនិងវិជ្ជាជីវៈសារព័ត៌មាន។

ស៊ីស៊ីអាយអឹម( CCIM ) ដែលជាអង្គការមិនមែនរដ្ឋាភិបាលលើកកម្ពស់សារព័ត៌មានឯករាជ្យ និងសេរីភាពបញ្ចេញមតិ និងខេមបូចា ( CamboJA )ដែលមានសមាជិកសមាជិកាជាអ្នកសារព័ត៌មានប្រមាណជាង១០០នាក់ ជំរុញជាថ្មីដល់រាជរដ្ឋាភិបាល ឱ្យបញ្ឈប់នូវសកម្មភាពរបស់សមត្ថកិច្ចដែលធ្វើទុកបុកម្នេញអ្នកសារព័ត៌មានដោយជំនួសមកវិញនូវការធានាសុវត្ថិភាពនិងសន្តិសុខដល់អ្នកសារព័ត៌មានគ្រប់រូប ដើម្បីឱ្យពួកគេអាចអនុវត្តសិទ្ធិសេរីភាព និងបំពេញវិជ្ជាជីវៈបានត្រឹមត្រូវ ដើម្បីចូលរួមរាយការណ៍ពីរឿងរ៉ាវ និងបទល្មើសនានាដែលកំពុងកើតមានឡើងនៅក្នុងសង្គមដោយមិនមានការភ័យខ្លាច៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក អ៊ិត សូធឿត នាយកនៃនាយកដ្ឋានប្រព័ន្ធផ្សព្វផ្សាយនៃ CCIM
ទូរសព្ទលេខ៖ ០១២ ៨១៩ ៥៤៥
អ៊ីមែល៖ isothoeuth@vodhotnews.com

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា ( ខេមបូចា )
ទូរសព្ទលេខ៖ ០១២ ៥១៩ ២៦១
អ៊ីមែល៖ ed@camboja.net